# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់
## មន្ទីរធនធានទឹក និងឧតុនិយម ខេត្តបន្ទាយមានជ័យ
## និង
## អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន (RCEDO) និង
## អង្គការអភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO)

**១.សេចក្តីផ្តើម៖**

អនុស្សរណៈយោគយល់នេះ គឺដើម្បីបង្កើតអោយមាន កិច្ចសហប្រតិបត្តិការរវាងមន្ទីរធនធានទឹកនិងឧតុនិយម និង **អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និង បរិស្ថាន (RCEDO) និង អង្គការ អភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO)** តាមរយៈ ការអនុវត្តគម្រោងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍ ជំហ៊ាន ២ ខែមេសា ២០១៨ ដល់ ខែមីនា ២០២១។

គោលបំណងគឺចូលរួមចំណែកធ្វើឲ្យប្រជាពលរដ្ឋក្នុងសហគមន៍កាន់តែមានលទ្ធភាពទទួលនូវការលើកកម្ពស់ជីវភាពរស់នៅតាមរយៈការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយធម្មជាតិដោយការបង្កើត ថែទាំ ប្រើប្រាស់ និងគ្រប់គ្រងប្រភព និងធនធានទឹកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃ និង កសិកម្ម អោយមានប្រសិទ្ធភាពហើយឆ្លើយតបនឹង គ្រោះមហន្តរាយទឹកជំនន់ និង រាំងស្ងួត។ កិច្ចសហប្រតិបត្តិការនេះ នឹងធ្វើអោយការអនុវត្តគម្រោង (CBDRR-II) កាន់តែមានប្រសិទ្ធភាព និង សំរេចបាននូវគោលដៅរួមរបស់គម្រោង ដែលស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល ស្តីពី ការបញ្ជ្រាបដោយប្រសិទ្ធភាពនូវការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងដំណើរការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចគ្រប់កម្រិត។

**២. គោលបំណង នៃ កិច្ចសហការ៖**

១- ពង្រឹងកិច្ចសហការជាដៃគូរ ក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសហគមន៍

២- ផ្តល់ជំនួយបច្ចេកទេស និង ពង្រឹងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងទឹក,សហគមន៍ប្រើប្រាសទឹកនិង អ្នកពាក់ព័ន្ធនានា។

៣-ចូលរួម ត្រួតពិនិត្យតាមដាន និង ផ្តល់អនុសាសន៍ដើម្បីអោយសកម្មភាពគម្រោងដែលទាក់ទងវិស័យធនធានទឹកកាន់តែប្រសើរឡើង ។

**៣. លទ្ធផលរំពឹងទុកនៃកិច្ចសហការក្នុងការអនុវត្តគម្រោង៖**

១)-ការអនុវត្តគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសហគមន៍មានដំណើរការល្អ មានប្រសិទ្ធភាព និង និរន្តរភាពគម្រោង ។